### ១-ការថែទាំ :

#### ក-ការស្រោចស្រព :

សណ្តែកកួរជាប្រភេទដំណាំដែលទាមទារទឹកមិនច្រើនដូចពពួកអំបូរស្លែទេ។ការស្រោចទឹកគេនិយមរែកស្រោចនៅក្នុងករណីកូនសណ្តែកនៅតូច ជាពិសេសពេលចេញផ្កានិងចាប់ផ្តើមចេញកួរ ពីព្រោះកាលណាយើងស្រោចទឹកមិនបានជិតដល់វាបណ្តាលឱ្យជ្រុះផ្កា និងកួរសណ្តែកក្បៀបគ្មានគ្រាប់ ។ ប៉ុន្តែនៅពេលសណ្តែកធំបន្តិច គេអាចបញ្ចូលទឹកតាមចន្លោះរងដោយលៃយ៉ាងណាឱ្យដីសើមល្មម បើសិនយើងបញ្ចូលទឹកច្រើនពេក អាចបណ្តាលអោយសណ្តែកយើងរលួយគល់ងាប់តែម្តង ។

#### ខ-ការសំអាតស្មៅ :

ការងារនេះយើងត្រូវធ្វើនៅពេលសណ្តែកមានអាយុ ១០-១៥ ថ្ងៃ ដោយលៃលកយ៉ាងណាកុំអោយប៉ះពាល់ដល់ប្រព័ន្ធឫសរបស់កូនសណ្តែកយើងត្រូវធ្វើជាប្រចាំរៀងរាល់សប្តាហ៍ បើឃើញមានស្មៅដុះ ។

#### គ-ការជ្រួយដី :

*ការជ្រួយដីមានពីរលើក គឺ:*

-*ជ្រួយដីលើកទី ១* : នៅពេលសណ្តែកមានអាយុប្រហែល ៧-១០ ថ្ងៃ ក្រោយពេលដាំនិងពូនគល់ដោយធ្វើយ៉ាងណាកុំឱ្យប៉ះពាល់ដល់ឫសរបស់វា ។

-*ជ្រួយដីលើកទី ២* : ធ្វើនៅមុនពេលដាក់ជីលើកទី ២ នៅពេលសណ្តែកមានអាយុប្រហែល៣០ ថ្ងៃក្រោយពេលដាំ ។

#### ឃ-ការដោតទ្រើង :

សណ្តែកកួរជាប្រភេទដំណាំដែលទាមទារឱ្យមានទ្រើងសំរាប់វារតោងឡើងក្នុងការដុះលូតលាស់របស់វា ការដោតទ្រើងនេះធ្វើយ៉ាងយូរបំផុត ១៥ ថ្ងៃ ក្រោយពេលដាំ ហើយកូនសណ្តែកមានសន្លឹកពី ៣-៥ ទ្រើងដែលត្រូវដោតមានកំពស់ ១ ម កន្លះ - ២ ម ត្រូវចងឱ្យកូនសណ្តែកនោះវារតោងឡើង ត្រូវពិនិត្យ នឹងចងបន្ថែមទៅតាមដំណើររបស់វា ។

#### ង-ការដាក់ជី :

ក្រៅពីការដាក់ជីទ្រាប់បាតដំណាំសណ្តែកកួរ គេត្រូវដាក់ជីបន្ថែមផងដែរ ជីបន្ថែមនេះគេត្រូវដាក់ ៣ សប្តាហ៍ ក្រោយពេលដាំ គឺក្នុងកំរិត ២០-៣០ ក្រាម ក្នុង១គុម្ព ចន្លោះពីគល់សណ្តែក ១៥-២០ ស.ម លើកទី២ គេដាក់នៅពេលចេញផ្កា ការដាក់ដូចជារបៀបទីមួយដែរ ។

#### ច-សត្វល្អិតចង្រៃនិងវិធានការការពារ :

នៅលើដំណាំសណ្តែកកួរ គេតែងជួបប្រទះសត្វល្អិតចង្រៃមួយចំនួនដូចជា :

-ពពួកចៃ

-ដង្កូវចោះផ្លែ

-ពីងពាងក្រហម

*វិធានការកំចាត់* :

ត្រូវពិនិត្យទៅលើកំលាំងបំផ្លាញរបស់សត្វល្អិតចង្រៃ បើមិនមានសភាពខ្លាំងក្លាទេ គេមិនចាច់កំចាត់វាទេ បើមានចៃតិចតួចគេអាចបូតដោយដៃ ។ល។ ការប្រើប្រាស់ថ្នាំគីមីត្រូវធ្វើនៅពេលមានការបំផ្លាញខ្លាំងក្លា និងជាដំណោះស្រាយចុងក្រោយប៉ុណ្ណោះ ។

*ថ្នាំពុលដែលត្រូវយកមកប្រើមាន* :

-ហ្វូរ៉ាដង់ ( Furadan ) ៣ ក្រាម ក្នុង ១០ ម$^{២}$

-ឌីយ៉ាស៊ីណុង ( Diazinon ) ១៥ សេសេ ក្នុង ៣ លីត្រ ទឹក ។

-មេវីនហ្វូស ( .Mevinphose ) ៣ សេសេ ក្នុង ១ លីត្រ ទឹក ។

-ស៊ូយមីស៊ីឌីន( Sumisudin ) ៣.៥ សេសេ ក្នុង ៣ លីត្រ ទឹក ។

## ២-ការប្រមូលផល :

ការប្រមូលផលប្រព្រឹត្តិទៅបាននៅអាយុកាល ៥០-៦០ ថ្ងៃ ក្រោយពេលដាំ គេអាចប្រមូលផលបានពីរដងក្នុងមួយសប្តាហ៍ ។ ត្រូវឧស្សាហ៍ពិនិត្យមើលការលូតលាស់របស់ផ្លែសណ្តែក មិនត្រូវទុកឱ្យវាចាស់ជ្រុលពេកទេ ព្រោះអាចលក់មិនដាច់ឬលក់មិនបានថ្លៃ ។ ផ្លែសណ្តែកពេញនិយមពេលនៅខ្ចីរស់ជាតិឆ្ងាញ់ និងអាចរក្សាទុកបានយូរជាងសណ្តែកដែលមានអាយុចាស់ ។ យើងអាចប្រមូលផលផ្លែដោយដៃ ឬ ដោយប្រើកន្ត្រៃសំរាប់កាត់ ។ ត្រូវប្រុងប្រយ័ត្ននៅពេលប្រមូលផលម្តងៗ ធ្វើយ៉ាងណាកុំឱ្យដាច់ដើម ឬប៉ះដល់ផ្កានាំឱ្យជ្រុះ គឺបាត់បង់ទិន្នផល ។ ក្នុងករណីយើងដាំបានល្អ យើងអាចប្រមូលផលបានទិន្នផលពី ២០-២៥ តោន ក្នុង ១ ហិកតា ។

## ៣-ការរក្សាទុកពូជ :

យើងត្រូវជ្រើសរើសផ្លែធំ គួរវែង រួចទុកផ្លែនោះអោយទុំស្ងួត ហើយយកទៅហាលអោយបាន ២-៣ ថ្ងៃ រួចច្រកស្បោងក្រណាត់ទុកកន្លែងដែលមានខ្យល់ចេញចូល ។



*ផលិតផលត្រូវបានយកមកលក់*



# ការដាំដំណាំសណ្តែកគួរ



គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍អាស៊ី (ADB) លេខ 1445-CAM ( SF )
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
លេខ : ១១ ឆ្នាំ ២០០២